# មេរៀនទី ៣២៖ ព្រះបានធ្វើឲ្យទឹកជំនន់លិចផែនដី

## លោកុប្បត្តិ ៧-៨, ៩៖៨-១៦

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/HKxowsFgRFQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/MeHDbLbN-jg

**គោលបំណង៖ យើងតែងតែអាចពឹងផ្អែកលើព្រះបាន។**

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ៣៣៖២០** *"ព្រលឹងនៃយើងខ្ញុំសង្ឃឹមដល់ព្រះយេហូវ៉ា ទ្រង់ជាជំនួយ ហើយជាខែលរបស់យើងខ្ញុំ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. លោកតាណូអេ https://youtu.be/97I8ePxrQ7s

២. ក្នុងពេលទ្រង់ https://youtu.be/uOmu3Qm5pr0

៣. ក្តីសុខសាន្ត https://youtu.be/N9mBBb9zljw

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ចំលងមិត្តភក្តិ»



សម្ភារៈដែលត្រូវការ៖ ខ្សែ

១. ឲ្យកុមារចាប់ដៃគូពីរៗនាក់ ហើយឈរជិតគ្នា

២. កុមារម្នាក់ត្រូវឈរបែរមុខមកខាងមុខ ហើយកុមារម្នាក់ទៀតត្រូវឈរបែរមុខ ទៅក្រោយ។ គ្រូនឹងឲ្យខ្សែទៅកុមារគ្រប់ក្រុម បន្ទាប់ពួកគេត្រូវចងជើងពួកគេ ម្នាក់ម្ខាងជាមួយគ្នា។

៣. នៅពេលដែលគ្រូនិយាយថា "១ ២ ៣ ទៅ" កុមារគ្រប់ក្រុមទាំងអស់ត្រូវដើរទៅកាន់ទី ហើយត្រឡប់មកវិញ។

៤. ក្រុមណាដែលអាចត្រឡប់កកាន់ទីចាប់ផ្តើមវិញដោយមានខ្សែជាប់ជើង នឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកយើងមិនអាចរស់នៅលើពិភពលោកនេះតែម្នាក់ឯង នោះទេ ហើយយើងត្រូវតែធ្វើការជាមួយគ្នា ដើម្បីធ្វើឲ្យជីវិតរស់នៅរបស់យើងប្រសើរឡើងជាមួយគ្នា។

### ៤. ការណែនាំមេរៀន

តើអ្នកណាចូលចិត្តលេងទឹកភ្លៀង នៅពេលមេឃភ្លៀងធ្លាក់ដែរឬទេ? តើអ្នកធ្លាប់មានបទពិសោធន៍ជាមួយទឹកជំនន់ជ្រៅជាងគេនៅរដូវភ្លៀងធ្លាក់ដែរឬទេ? សូមស្រមើស្រម៉ៃមើលថាតើកំពស់ទឹកជំនន់អាចខ្ពស់ ជាងភ្នំដែរឬទេ? ថ្ងៃនេះយើងនឹងរៀន ពីគ្រួសារមួយដែលទុកចិត្តព្រះឲ្យទ្រង់ថែរក្សាពួកគេក្នុងពេលមានទឹកជំនន់ដ៏ធំ!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

សប្តាហ៍មុន យើងបានរៀនពីមនុស្សដែលនៅតែប្រព្រឹត្តអំពើបាប និងឈប់ស្តាប់បង្គាប់ព្រះដែលធ្វើឲ្យព្រះមិនសព្វព្រះទ័យ។ ព្រះបានប្រាប់ណូអេឲ្យសាងសង់ទូកដ៏ធំមួយ ពីព្រោះទ្រង់ចង់កំចាត់មនុស្សមានបាប

ទាំងអស់ចោល។ ណូអេ និងគ្រួសាររបស់គាត់ រួមជាមួយនឹងសត្វទាំងអស់បានដើរចូលទៅក្នុងទូក ហើយទ្វារក៏បានបិទ។ ទោះជានៅពេលដែលមនុស្សបានឃើញគ្រប់ទាំងសត្វទាំងអស់បានដើរចូលទៅក្នុងទូក មនុស្សទាំងអស់នៅតែមិនបានប្រែចិត្ត ហើយមិនបានជឿលើព្រះ។ ប៉ុន្តែណូអេ និងក្រុមគ្រួសារគាត់បានដឹងថា ពួកគេនៅតែអាចទុកចិត្តព្រះ ដូច្នេះពួកគេបានស្តាប់បង្គាប់ព្រះ។

ព្រះគម្ពីរបានប្រាប់ថា បន្ទាប់ពីណូអេ និងក្រុមគ្រួសារបានចូលទៅក្នុងទូក មេឃក៏ចាប់ផ្តើមភ្លៀង។ មេឃធ្លាក់ភ្លៀងរយៈពេល៤០ថ្ងៃ៤០យប់ជាប់គ្នា។ ទឹកភ្លៀងក៏ចាប់ផ្តើមជន់ឡើង ហើយទូកក៏ចាប់ផ្តើម អណ្តែតនៅលើទឹកជំនន់។ ណូអេ និងក្រុមគ្រួសារបានពឹងផ្អែកលើព្រះដើម្បីឲ្យទ្រង់ថែរក្សាពួកគេឲ្យមានសុវត្ថិភាព។ ដូចដែលទឹកចាប់ផ្តើមជន់ខ្ពស់ទៅៗ ហើយទូកក៏បានអណ្តែតនៅលើទឹក។ ទឹកក៏កាន់តែចំរើនឡើងជាលើសលុបទាល់តែលិចអស់ទាំងភ្នំទាំងឡាយអស់រលីងទៅ។ នៅតែណូអេ និងគ្រួសាររបស់គាត់មានសុវត្ថិភាព។ ពួកគេមិនភ័យខ្លាចអ្វីឡើយ ពីព្រោះពួកគេដឹងថាពួកគេអាចពឹងផ្អែក លើព្រះបាន។

បន្ទាប់ពី៤០ថ្ងៃ៤០យប់កន្លងទៅ ភ្លៀងក៏ឈប់ធ្លាក់មក។ ណូអេ ក្រុមគ្រួសារគាត់ និងសត្វទាំងអស់ក៏មានសុវត្ថិភាពនៅក្នុងទូក។ ទូកបានអណ្តែតនៅលើមហាសាគរដ៏ធំល្វឹងល្វើយ។ ទីប្រជុំជន ទីក្រុង ភ្នំ និងចំការទាំងអស់បានគ្របដណ្តប់ពេញដោយទឹក។ បន្ទាប់ពីច្រើនថ្ងៃកន្លងទៅ ព្រះបានបញ្ជូនខ្យល់បក់មកលើផែនដី និងធ្វើឲ្យទឹកស្រកវិញ។ ពេលដែលទឹកចាប់ផ្តើមស្រក ទូកក៏បានគៀងនៅលើកំពូលភ្នំអារ៉ារ៉ាត់។

ណូអេបានលែងព្រាបមួយចេញមកក្រៅ។ ប៉ុន្តែសត្វព្រាបមិនអាចរកកន្លែងណាទំបានទេ ដូច្នេះហើយវាក៏បានត្រឡប់ទៅវិញ។ ១សប្តាហ៍ក្រោយមកណូអេបានព្យាយាមម្តងទៀត។ ពេលនេះសត្វព្រាបបានត្រឡប់មកវិញហើយបានពាំស្លឹកអូលីវមកជាមួយ។ ដូច្នេះណូអេបានដឹងថាទឹកមិនបានលិចគ្របលើដើមឈើទៀតទេ។ ហើយឆាប់ៗនេះដីក៏នឹងស្ងួតវិញដែរ។

បន្ទាប់ពីមួយសប្តាហ៍ក្រោយមក ណូអេបានលែងព្រាបទៅម្តងទៀត ហើយលើកនេះព្រាបនោះមិនបានត្រឡប់មកវិញទេ ពីព្រោះដីបានស្ងួតហើយ និងមានដើមឈើជាច្រើន។ ពេលដែលមានសុវត្ថិភាពហើយដីបានស្ងួតផងអស់ហើយ ព្រះបានមានបន្ទូលប្រាប់ណូអេឲ្យចេញមកក្រៅ។ ព្រះបានសន្យាជាមួយណូអេថាទ្រង់នឹងមិនបំផ្លាញផែនដីនេះដោយទឹកជំនន់ទៀតទេ។ ដូចដែលបានរំលឹកពីការសន្យារបស់ទ្រង់ព្រះបានដាក់ឥន្ទធនូនៅលើមេឃជាទីសំគាល់ នៅពេលដែលយើងឃើញឥន្ទធនូ វានឹងរំលឹកយើងថាយើងអាចនិងពឹងផ្អែកលើព្រះបានដែលទ្រង់តែងតែរក្សាការសន្យារបស់ទ្រង់។

យើងអាចពឹងផ្អែកលើព្រះបាន។ យើងតែងតែអាចទុកចិត្តព្រះឲ្យស្រឡាញ់យើង ឲ្យដឹកនាំជីវិតយើង ហើយមានពេលសំរាប់យើង។ ព្រះរក្សាការសន្យារបស់ទ្រង់គ្រប់ពេល។ ព្រះធ្វើអស់ពីសមត្ថភាពទ្រង់សំរាប់យើងគ្រប់ពេល។ មិនដែលមានហេតុផលណាដែលយើងសង្ស័យថាតើព្រះនៅទីនេះទេ ឬក៏សង្ស័យថាតើព្រះបានភ្លេចយើងហើយនោះទេ។ ព្រះបំភ្លឺពន្លឺរបស់ទ្រង់សំរាប់យើងគ្រប់ពេល ពីព្រោះព្រះតែងតែអាចពឹងផ្អែកបាន។

## ៦. សំនួរពិភាក្សា

១. តើមានភ្លៀងធ្លាក់រយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីណូអេ ក្រុមគ្រួសារគាត់ និងសត្វទាំងអស់បានចូលទៅក្នុងទូកហើយ? *(រយៈពេល៤០ថ្ងៃ៤០យប់)*

២. តើអ្នកណាសន្យាថានឹងក្សាឲ្យណូអេ ក្រុមគ្រួសារគាត់ និងសត្វទាំងអស់មានសុវត្ថភាព? *(ព្រះ)*

៣. ហេតុអ្វីបានជាណូអេ និងក្រុមគ្រួសារគាត់មិនភ័យខ្លាចក្នុងពេលមានទឹកជំនន់? *(ពីព្រោះពួកគេបានដឹងថាគេអាចនឹងពឹងផ្អែកលើព្រះបាន)*

៤. តើមានអ្វីខ្លះនៅក្នុងជីវិតរបស់អ្នកដែលអ្នកអាចនឹងពឹងផ្អែកលើព្រះឲ្យជួយអ្នកបាន?
*(សូមឲ្យកុមារឆ្លើយ)*

**៧. ល្បែងកំសាន្ត** «ផញ្ញូនចានប្រណាំងគ្នា»



សម្ភារៈដែលត្រូវការៈ ចានក្រដាស

១. ចែកកុមារជាពីក្រុមហើយឲ្យចានមួយ ទៅគ្រប់ក្រុមទាំងអស់

២. ឲ្យកុមារឈរជាឈរ ហើយកុមារទី១ ត្រូវដាក់ចានក្រដាសនៅចន្លោះជើង ហើយដើរទៅកាន់កុមារបន្ទាប់ ដែលឈរ(ចម្ងាយ ២ម៉ែត្រពីគ្នា)។ ពួកគេត្រូវបន្តបញ្ជូនចាននោះឲ្យទៅដល់កុមារចុងក្រោយ ដោយមិនប្រើដៃនោះទេ។

៣. ក្រុមណាដែលអាចបញ្ជូនចាននោះទៅដល់កុមារចុងក្រោយបានមុនគេក្រុមនោះជាអ្នកឈ្នះ

៤. បន្ទាប់ក្រុមដែលឈ្នះទាំងពីរត្រូវប្រកួតគ្នាម្តងទៀត ដើម្បីស្វែងរកអ្នកឈ្នះចុងក្រោយ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាមិនងាយស្រួលនោះទេក្នុងការបញ្ជូនចានក្រដាសនៅកាន់សមាជិកក្រុមដោយមិនប្រើដៃនោះ។ វាគឺមិនងាយស្រួលទេសម្រាប់ណូអេក្នុងការប្រមូលសត្វទាំងអស់ អាហារ ក្នុងរយៈពេល៤០ថ្ងៃមកក្នុងទូកនោះ។ ប៉ុន្តែគាត់នៅតែស្តាប់បង្គាប់ព្រះ ពីព្រោះគាត់ទុកចិត្តលើព្រះ។

**៨. ខគម្ពីរចងចាំ**

**ទំនុកដំកើង ៣៣:២០** *"ព្រលឹងនៃយើងខ្ញុំសង្ឃឹមដល់ព្រះយេហូវ៉ា ទ្រង់ជាជំនួយ ហើយជាខែលរបស់យើងខ្ញុំ។"*

**៩. ហត្ថកម្ម** «ណូអេពឹងផ្អែកលើព្រះ»

សម្ភារៈដែលត្រូវការៈ បោះពុម្ពក្រដាសហត្ថកម្ម កូល័រផាត់ពណ៌ កន្ត្រៃ និងការជ័រ



១ ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យពួកគេផាត់ពណ៌ឥន្ទធនូ ទូក និងសត្វទាំងអស់។

២ កាត់រូបរង្វង់ និងទូកចេញមក។ បត់រូបរង្វង់នោះជាពីរ ហើយយករូបទូកទៅបិតនៅខាងលើរង្វង់នោះ។

៣ អ្នកអាចបិតឲ្យរូបនោះឈរបាន ហើយធ្វើឲ្យវាមានចលនាបានដោយប្រើស្កុតបិតនៅខាងចុងរូបទូក។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះការសន្យា? តើអ្នកអាចរក្សាសន្យាបានទេ? តើអ្នកអាចទុកចិត្តមិត្តភក្តិអ្នកបានទេ? តើអ្នកណាធ្វើការសន្យាជាមួយអ្នក? ពេលដែលព្រះធ្វើការសន្យា អ្នកអាចទុកចិត្តថានឹងមិនមានអ្វីនៅលើផែនដីអាចបញ្ឈប់ព្រះក្នុងការរក្សាសន្យារបស់ទ្រង់បានឡើយ។ ការសន្យារបស់ព្រះនាំមកនូវការកំសាន្តចិត្ត ក្តីសង្ឃឹម និងសន្តិភាព។ សូមគិតពីការសន្យាទាំងអស់ដែលព្រះបានរក្សានៅក្នុងព្រះគម្ពីរ។ អរព្រះគុណព្រះសំរាប់ការរក្សាការសន្យារបស់ទ្រង់!

# ណូអេពឹងផ្អែកលើព្រះ







សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម ក្ដារផាត់ពណ៌ កន្ត្រៃ និងការជ័រ
១ ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យពួកគេផាត់ពណ៌ឥន្ទធនូ ទូក និងសត្វទាំងអស់។
២ កាត់រូបរង្វង់ និងទូកចេញមក។ បត់រូបរង្វង់នោះជាពីរ ហើយយករូបទូកទៅបិតនៅខាងលើរង្វង់នោះ។
៣ អ្នកអាចបិតឲ្យរូបនោះឈរបាន ហើយធ្វើឲ្យវាមានចលនាបានដោយប្រើស្កុតបិតនៅខាងចុងរូបទូក។